# រឿង មហាចោរនៅទល់ដែន

### ភាគទី២៥

កាលមានន្ទ បានទឹកផឹកឆ្អែតឆ្អន់ហើយ អ្នកបំផាយសេះ ទៅភូមិរហាត់ទឹក ដោយបោល កាត់តាមវាលស្រែ ដ៏ធំល្វឹងល្វើយ។ អ្នកបានប្រាប់គេថា អ្នកធ្វើដំណើរទៅបាត់ដំបង ។ ប្រាប់ យ៉ាងនេះ ដើម្បីបង្វែងដានទេ។ ដល់ចុងភូមិរហាត់ទឹកនេះ បុរសបំបោលសេះ តម្រង់ទៅផ្ទះ មួយតូច ដែលសង់ដាច់ពីគេនៅកៀនព្រៃ។ បុរសម្នាក់ អាយុប្រមាណសែសិបឆ្នាំ កាន់ចន្ទុះ មួយ ចេញមក។ លុះឃើញស្គាល់ដាក់ថា អ្នកជិះសេះជាមានន្ទ អ្នកកាន់ចន្ទុះ ក៏គ្រវីចន្ទុះ ឡើង រីករាយ ហើយស្រែកថា៖

- អា ! ជយោលោកគ្រូ ! ជយោលោកគ្រូ មកពីណា ?

ក្នុងសេចក្តីរីករាយនេះ ទាំងកាយ ទាំងវាចា របស់អ្នកកាន់ចន្ទុះ គេសង្កេតឃើញ នូវការ គោរពស្រលាញ់ យ៉ាងខ្ជាប់ខ្ជួន ជ្រាលជ្រៅ។ មានន្ទសំរូតចុះពីលើខ្នងសេះ ដោយអស់កម្លាំង ខ្លាំងពេក។ មាណពស្ទុះទៅឱបសហជីវិនចាស់ របស់អ្នក យ៉ាងខ្លាំង ដោយក្តីរលឹក។ មិត្តចាស់ នេះ ឈប់ធ្មឹង បាត់សើចសប្បាយវិញ រួចសួរយ៉ាងស្លូតថា៖

*ឱ ! លោកគ្រូរបួសផង ?

- ថាហើយអ្នកម្ចាស់ផ្ទះ ស្ទុះទៅគ្រាហ៍មានន្ទ ដោយថ្នាក់ថ្នម។

មានន្ទញញឹមឆ្លើយថា៖ អឺ ! ខ្ញុំរបួស!

- អ្នកណា អាចកាប់លោកគ្រូ ត្រូវយ៉ាងនេះ ?

មានន្ទញញឹមទៀត ។ បុរសកាន់ចន្ទុះផ្លាស់ទឹកមុខ ពីស្រពោន ទៅចង់ចិញ្ចើម។ សម្លេង មួយ បន្លឺលាន់ឮឡើង តិចៗ ថា៖

- ក្នុងភូមិភាគនេះ មានតែលោកគ្រូមួយទេ ម្តេចក៏មករបួសយ៉ាងនេះ មកឆាប់អញ្ជើញ លោកគ្រូចូលខាងក្នុងភ្នាម។

អត្ថបទដោយ៖ មាស សុភាព

- អឺ ! ឆាប់ឡើង!
- មានការឬទេ ?
- ប្រហែលមាន បងគឹងឯងសុខសប្បាយជាទេ ?
- សុខ និង ទុក្ខ ជាធម្មតា តែកុំអាលសិន សម្រាន្តលើគ្រែនេះផ្អែកទៅនឹងខ្នើយ ចាំខ្ញុំដាំទឹកលាងឈាមឲ្យស្អាត រួចចាំខ្ញុំ រុំរបួសឲ្យស្រួល មើលៗ តើមុខរបួសធំទេ !
- មិនអីទេ ?
- ឱ ! ព្រះអើយ ! ធំដែរ ម្ដេចឈឺទេ លោកគ្រូ ឈឺខ្លាំង ឬ ?

មានន្ទប្រឹងធ្វើមុខជូរ តែអ្នក ខំប្រឹងញញឹម ឲ្យសហជីវិនរបស់អ្នក បានធូរទ្រូង។

- មិនជាអ្វីទេ!
- លោកគ្រូ សម្រាន្តនៅឲ្យស្ងៀម ទុកខ្ញុំធ្វើការនេះ។

នាយអគ្គីឆ្វេឆ្វា រហ័សជើង ស្ទុះចូលទៅក្នុងផ្ទះបាយ ដុតភ្លើង ដាំទឹក ឆេះឲ្យទង្គោល រួចមកប្រប៉ាច់ដៃជើងឲ្យមានន្ទ ។ នាយអគ្គីនិយាយ ស្ទើរយំ ថា៖

- ខ្ញុំនឹកលោកគ្រូណាស់។ យើងព្រាត់គ្នាយូរមកហើយ លោកគ្រូបានសុខសប្បាយជាទេ សូមនិយាយរឿងប្រាប់ខ្ញុំផង។
- បងគឹងឯងជាមិត្តជីវិតមួយ នឹងខ្ញុំ ។ ខ្ញុំក៏នឹករលឹកបងណាស់ដែរ តាំងពីយើងបែកគ្នាមក។ ថ្ងៃនោះ តើបងគឹភ្លេចហើយឬនៅ?
- អឺ! គ្មានអ្នកណាអាចភ្លេចបានទេ ភ្លៀងស្រិបៗ ខ្យល់រូៗ គេដេញបាញ់យើង។ បងគឹងឯងបែកទៅខ្ញុំ តដៃនឹងខ្មាំង សម្លាប់អស់ជាច្រើន ដល់មានឱកាសល្អ ខ្ញុំគេចផុតឆ្ងាយពីសត្រូវៗ ខ្ញុំរត់រកបងគឹងឯងគ្រប់កន្លែង ស្រែកហៅ តែពុំឃើញ ខ្ញុំខ្លោចចិត្ត នឹកថា បងគឹងឯងស្លាប់បាត់ទៅហើយ។ ផុតពីនោះ ខ្ញុំក៏ចូលទៅនៅសិរីសោភ័ណ។ ខ្ញុំសុខសប្បាយជាទេ ពីនោះមក ខ្ញុំមានប្រពន្ធ . . .។

បុរសឈ្មោះអគ្គី កាលឮមានន្ទថ្លែងថាមានប្រពន្ធ ក៏ប្រែជាសប្បាយសើចយ៉ាងស្រស់វិញ។

អត្ថបទដោយ៖ មាស សុភាព

- យី ! អីលោកគ្រូមានប្រពន្ធហើយ ?

តែមានន្ធធ្វើទឹកមុខស្មើដដែល។

- អឺ ! កុំអរ . . កុំសើច . . គឺជារឿងកម្សត់ . . ខ្ញុំស្រលាញ់គេ គេស្រលាញ់ខ្ញុំ គ្មានសេចក្តីស្នេហាឯណា អាចមកប្រៀបធៀប នឹងសេចក្តីស្នេហា របស់យើងទាំងពីរនោះទេ ។ នាងនោះមានរូបល្អ ។ ឱ! ល្អមែន . . .។

នាយគីទះដៃដោយត្រេកអរ។

- លោកគ្រូមានសំណាងណាស់!

មានន្ធសញ្ជឹងគិត ខាំធ្មេញ ជ្រួញភ្នែក សម្លឹងមើលទៅលើ។

- ទេ ! មិនដូច្នោះទេ ! ក្រោយមកស្រីនេះ......ឱ ! បង អើយ.... ស្រីនេះក្បត់ខ្ញុំ គេលួចមានសហាយ។

- អី....បង បង មានសហាយ . . . ?

នាគីប្រែទឹកមុខ ស្រឡាំងកាំង បើកភ្នែកធំ។

- យី ! ម៉េចក៏ដូច្នោះ ?

មានន្ធ ដោយទឹកមុខស្លូតដដែល និយាយដោយសម្លេងម្ហូលដដែល ថា៖

- កុំឆ្ងល់ ស្រីខូច ស្រីកាឡកណ្ណី ស្រីអប្បលក្ខណ៍។

នាយគីងាកក្បាលសម្លឹងគិត រួចសួរថា៖

- អ្នកណាជាសហាយ ?
- ខ្ញុំនិយាយទៅវាស្ងាក់ ខ្ទាក់ទៅវាស្ងែង គឺ . . . សហាយនោះគ្មានអ្នកឯណាក្រៅពីខ្ញុំទេ គឺសាច់ខ្ញុំ . . . ឈាមខ្ញុំ សរសៃខ្ញុំ . . .អ្នកណា ? អ្នកណា ?

(សូមរង់ចាំតាមដានភាគទី២៦ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព